# ដំណាំត្រាវ

Taro



ត្រាវជាប្រភេទបន្លែមួយបែប ដែលប្រជាកសិករយើងនិយមបរិភោគ ព្រោះគេអាចច្នៃធ្វើជាម្ហូបអាហារព្រមទាំងបង្អែមបានយ៉ាងច្រើន។ ធាង និង ស្លឹកខ្ចីរបស់វាជាបន្លែម្យ៉ាង ដែលអាចយកច្នៃធ្វើជាសម្លរបានយ៉ាងឆ្ងាញ់ពិសារ។ធាងបណ្ដូល ស្លឹកខ្ចីៗ និង ដៃត្រាវក៏ចាត់ចូលជាពពួកបន្លែបៃតងដែលក្នុងនោះសំបូរទៅដោយវីតាមីនអា សម្រាប់ការការពារជម្ងឺខ្វាក់មាន់ និងភ្នែកឡើងបាយរបស់កុមារ និងមនុស្សធំទៀតផង។

## I.លក្ខខណ្ឌបរិស្ថាន

### ១.លក្ខខណ្ឌដី

ដំណាំត្រាវជាប្រភេទដំណាំ ដែលអាចដាំដុះលូតលាស់បានល្អប្រសើរលើប្រភេទដីឥដ្ឋស្រាល ដែលសំបូរទៅដោយសារធាតុចិញ្ចឹមគ្រប់មុខ ជាពិសេសគឺជាតិកំបោរជ្រាបទឹករហ័សព្រមទាំងសំបូរទៅដោយសារធាតុខនិជ។ ប្រភេទដីល្បាយខ្សាច់ ត្រាវអាចដុះលូតលាស់បាន និង ចាក់ឫសបានជ្រៅ ប៉ុន្តែការផ្គត់ផ្គង់ទឹក និង ជី ត្រូវអនុវត្តតាមវិធីសាស្ត្រណែនាំត្រឹមត្រូវទើបទទួលបានទិន្នផលខ្ពស់។ នៅលើប្រភេទដីខ្មៅហើយស្ថិតជាមធ្យមនៅរដូវភ្លៀង ត្រូវមានប្រព័ន្ធប្រឡាយបញ្ចេញ

ទឹក។ ជាទូទៅត្រាវអាចដុះលូតលាស់លើប្រភេទដីស្ទើរគ្រប់ប្រភេទ ក្នុងករណីប្រភេទដីឥដ្ឋធម្មតា ត្រូវមានប្រព័ន្ធប្រឡាយរំដោះទឹកត្រឹមត្រូវព្រមទាំងការជ្រើសរើសពូជឲ្យបានល្អ។





ទិដ្ឋភាពចម្ការត្រាវ

## ២.ពន្លឺ

ដំណាំត្រាវត្រូវការពន្លឺថ្ងៃពីចាប់ពី ៩ ទៅ ១០ ម៉ោង ក្នុង២៤ម៉ោង ជួយជម្រុញឲ្យការលូតលាស់ និងជួយបង្កើនទិន្នផលពី២១ ទៅ ២៥% និងបង្កើនគុណភាពឥទ្ធិពលនៃពន្លឺធ្វើឲ្យមានភាពបៃតងចាស់។

## II.បច្ចេកទេសដាំដុះ

### ១ ប្រភេទដី:

☞ **អំពីដី** ត្រាវជាប្រភេទដំណាំយកមើម ដែលអាចដុះលូតលាស់នៅក្នុងស្រទាប់ដីប៉ែកខាងលើ ម៉្យាងទៀតវាជាប្រភេទដំណាំដែលមានវដ្តជីវិតវែង ដូចនេះគឺតម្រូវការដីដែលមានជីវជាតិគ្រប់គ្រាន់។ លក្ខខណ្ឌដែលសមស្របសម្រាប់ធ្វើការដាំដុះគឺដីធូរ ជ្រាបទឹកបានល្អ ស្រទាប់ដាំដុះជ្រៅ ភាគរយដីខ្សាច់ច្រើនជាងដីកណ្តោង និង ដីឥដ្ឋ ជា